## មាតិកា


**១. សេចក្តីផ្តើម** ........ 1

**២. ទស្សនវិស័យ និងគោលបំណង** ........ 2

២-១. ទស្សនវិស័យនៃផែនការគ្រប់គ្រង ........ 2

២-២. គោលបំណង ........ 3

**៣. ស្ថានភាពសេដ្ឋកិច្ចសង្គម** ........ 3

៣-១. សមាជិក និងកម្រិតជីវភាព ........ 3

៣-២. ស្ថានភាពសន្តិសុខស្បៀង ........ 4

៣-៤. សមិទ្ធផលសំខាន់ៗដែលសហគមន៍សម្រេចបានកន្លងមក ........ 5

៣-៥. បញ្ហាកំពុងជួបប្រទះ ........ 5

**៤ .ស្ថានភាពទូទៅនៃធនធានរបស់សហគមន៍** ........ 5

៤-១. ធនធានធម្មជាតិក្នុងតំបន់ព្រៃសហគមន៍ ........ 5

៤-២. តម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើនៅក្នុងសហគមន៍ ........ 6

**៥. យុទ្ធសាស្ត្រនៃការគ្រប់គ្រង** ........ 7

៥-១. រចនាសម្ព័ន្ធគ្រប់គ្រង ........ 7

៥-២. ការបែងចែកតំបន់គ្រប់គ្រង និងប្រើប្រាស់ ........ 7

៥-២. គោលការណ៍ប្រើប្រាស់ធនធានធម្មជាតិ ........ 8

៥-៣. គោលការណ៍បែងចែកផលប្រយោជន៍ ........ 9

៥-៤. គោលការណ៍ស្វែងរកថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុ ........ 9

**៦. ផែនការសកម្មភាពសំខាន់ៗសម្រាប់អនុវត្តរយៈពេល៥ឆ្នាំ(២០១៨-២០២២)** ... 11

**៧. យន្តការត្រួតពិនិត្យ និងវាយតម្លៃ** ........ 19

**៨. តារាងឧបសម្ព័ន្ធ** ........ 22

## ១. សេចក្តីផ្តើម

សហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១១ ក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការបំរើមិត្តភ័ក្ដិអាមេរិកកាំង(AFSC) សហការជាមួយឧទ្យានជាតិបុទុមសាគរ មន្ទីរបរិស្ថានខេត្ត ព្រមទាំងអាជ្ញាធរមូលដ្ឋាន។ សហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក គ្រប់គ្រងលើទំហំផ្ទៃដី**១២៨៦ហិកតា** និងមានប្រកាសទទួលស្គាល់ដោយក្រសួងបរិស្ថានលេខ០១៨ ប្រក.បស្ថ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ របស់ក្រសួងបរិស្ថាន ។

សហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹកមានការចូលរួមពីប្រជាពលរដ្ឋចំនួន ៥ភូមិ រួមមានៈ ភូមិតាមាឃ ភូមិតាអុក ភូមិត្រេះ ភូមិប្រទាល និងភូមិប្រៃ ឃុំអណ្តូងទឹក ស្រុកបុទុមសាគរ នៃឧទ្យានជាតិបុទុមសាគរ ខេត្តកោះកុង ដែលមានសមាជិកចូលរួមសរុបចំនួន ៤៦២គ្រួសារ និងមានប្រជាជនសរុបចំនួន១៦០០នាក់ ស្រី៨៨៣នាក់។ បច្ចុប្បន្នមានចំនួនសមាជិក**៦៣៣គ្រួសារ** និងមានប្រជាពលរដ្ឋសរុបចំនួន**២៧០២នាក់ ស្រី១៣៣៥នាក់**។

នៅក្នុងដំណើរការគ្រប់គ្រងនេះ សហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក បានខិតខំអនុវត្តកិច្ចការងារជាច្រើន ដូចជា ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ការបោះបង្គោលព្រំប្រទល់សហគមន៍ ការដាក់ស្លាកសញ្ញាផ្សព្វផ្សាយ ការរៀបចំលក្ខន្តិកៈសហគមន៍ ការថែទាំដំណុះកូនកោងកាងធម្មជាតិ ការដាំស្តារព្រៃកោងកាង ការរៀបចំចងក្រងក្រុមសន្សំប្រាក់នៅក្នុងសហគមន៍ ព្រមទាំងបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងបរិស្ថានផងដែរ ។ ជាលទ្ធផល សហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក ទទួលបាននូវសិទ្ធិពេញលេញក្នុងការគ្រប់គ្រង និងប្រើប្រាស់ផល-អនុផលព្រៃឈើសម្រាប់ការដោះស្រាយជីវភាពប្រចាំថ្ងៃរបស់សមាជិកសហគមន៍។ ក្រៅពីលទ្ធផលដែលទទួលបានខាងលើ សហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក ក៏មានការកើនឡើងនូវសមាជិកសហគមន៍ ព្រមទាំងសមត្ថភាពក្នុងការគ្រប់គ្រងផងដែរ តាមរយៈការចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេស។

ទោះបីជាសហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក ទទួលបាននូវសមិទ្ធផលជាច្រើនយ៉ាងណាក្តី ក៏សហគមន៍ នៅមានបញ្ហាមួយចំនួនកំពុងជួបប្រទះនៅក្នុងដំណើរការគ្រប់គ្រងរបស់ខ្លួនផងដែរ ដូចជា សមត្ថភាពរបស់គណៈកម្មការនៅក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅមានកម្រិត បញ្ហាបទល្មើសនេសាទនៅក្នុងតំបន់សហគមន៍ សមាជិកសហគមន៍នៅមិនទាន់ស្គាល់ច្បាស់ពីព្រំប្រទល់សហគមន៍ បញ្ហាអនាម័យនៅក្នុងសហគមន៍ កង្វះធនធានមនុស្ស កង្វះមធ្យោបាយ និងសម្ភារៈសម្រាប់អនុវត្តន៍។

ដើម្បីឆ្លើយតបទៅនឹងទិដ្ឋភាពច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ក្នុងមាត្រា២៨ ដែលតម្រូវឱ្យសហគមន៍មានផែនការគ្រប់គ្រងស្របជាមួយនឹងទិសដៅក្នុងការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង សហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក បានឈានដល់ការខិតខំរៀបចំផែនការគ្រប់គ្រងរយៈពេល៥ឆ្នាំ(២០១៨-២០២២) ដែលក្នុងនោះ សហគមន៍បានធ្វើការសិក្សាប៉ាន់ប្រមាណពីតម្រូវការប្រើប្រាស់ផល-អនុផលព្រៃឈើរបស់

សមាជិក និងការសិក្សាប៉ាន់ប្រមាណធនធានព្រៃឈើនៅក្នុងសហគមន៍ តាមរបៀបធ្វើសារពើភ័ណ្ឌព្រៃឈើ។ លទ្ធផលនៃការសិក្សាទាំងនោះបានផ្តល់នូវព័ត៌មាន និងទិន្នន័យជាមូលដ្ឋានសម្រាប់ពិគ្រោះយោបល់ក្នុងការរៀបចំផែនការគ្រប់គ្រងរយៈពេលប្រាំឆ្នាំ(២០១៨-២០២២)។

ផែនការគ្រប់គ្រងនេះ គឺជាសមិទ្ធផលថ្មីមួយទៀត ដែលសហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹកសម្រេចបានព្រោះថាផែនការគ្រប់គ្រងនេះ កើតមានឡើងតាមរយៈកិច្ចខិតខំប្រឹងប្រែង និងការចូលរួមរបស់សហគមន៍ហើយផែនការគ្រប់គ្រងនេះ គឺជាប្រទីបមួយសម្រាប់ចង្អុលបង្ហាញដល់ការអនុវត្តរបស់សហគមន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការងារអភិវឌ្ឍន៍របស់សហគមន៍។ លើសពីនេះទៀតផែនការគ្រប់គ្រងសហគមន៍នេះ ក៏ជាមធ្យោបាយមួយសម្រាប់ទាក់ទាញប្រភពថវិកាពីគម្រោង ដៃគូអភិវឌ្ឍ ឬសប្បុរសជនដែលមានបំណងជួយគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍ និងគ្រប់គ្រងធនធានធម្មជាតិរបស់សហគមន៍ផងដែរ។

ម៉្យាងវិញទៀត ផែនការគ្រប់គ្រងនេះពិតជានៅមានភាពខ្វះចន្លោះ ព្រោះថានេះជាលើកទីមួយដែលសហគមន៍បានរៀបចំឡើង។ ទោះបីជាយ៉ាងណា តាមរយៈនៃការអនុវត្តផែនការគ្រប់គ្រងនេះ សហគមន៍ពិតជាបានរៀនសូត្រ និងកែលម្អលើសកម្មភាពគ្រប់គ្រង ដោយផ្អែកតាមយន្តការត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំនីមួយៗ។

## ២. ទស្សនវិស័យ និងគោលបំណង

### *២-១.ទស្សនវិស័យនៃផែនការគ្រប់គ្រង*

ដោយពិនិត្យទៅលើបញ្ហាដែលកំពុងជួបប្រទះនៅក្នុងដំណើរការគ្រប់គ្រង សហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក បានកំណត់នូវទស្សនវិស័យ សម្រាប់ការអនុវត្តផែនការគ្រប់គ្រងលើកទីមួយសម្រាប់ឆ្នាំ (២០១៨-២០២២) ពោល គឺ ធ្វើឱ្យប្រសើរឡើងទាំងកម្រិតជីវភាពរស់នៅរបស់សមាជិក និងធនធានព្រៃនៅក្នុងសហគមន៍។

ដើម្បីសម្រេចបានទស្សនវិស័យនេះ សហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក បានកំណត់នូវយុទ្ធសាស្ត្រសំខាន់ៗសម្រាប់ការអនុវត្តផែនការគ្រប់គ្រងលើកទីមួយ(២០១៨-២០២២) ដូចខាងក្រោម៖

- ស្តារឡើងវិញនូវតំបន់ព្រៃវិចវិល តាមរយៈការថែរក្សាកូនដំណុះធម្មជាតិ និងការដាំស្តារកូនកោងកាងបន្ថែម
- ធ្វើឱ្យសមាជិកសហគមន៍មានជីវភាពប្រសើរជាងមុន តាមរយៈការរៀបចំក្រុមសន្សំប្រាក់
- ធ្វើឱ្យសមាជិកសហគម៍រស់នៅប្រកបដោយសុខមាលភាពតាមរយៈការរៀបចំឱ្យមានអណ្តូងទឹក ការសាងសង់បង្គន់អនាម័យសំរាប់ប្រើប្រាស់នៅតាមគ្រួសារ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ទំនប់ទឹកប្រៃ និងស្ពាននៅក្នុងសហគមន៍ផងដែរ

- ធ្វើឱ្យសមាជិកសហគមន៍មានភាពជាម្ចាស់ក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងសហគមន៍ តាមរយៈការពង្រឹងនូវសមត្ថភាព និងអភិបាលកិច្ចក្នុងការគ្រប់គ្រងសហគមន៍ ។

### *២-២ .គោលបំណង*

ការរៀបចំផែនការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក ធ្វើឡើងក្នុងគោលបំណងជាក់លាក់ ដូចខាងក្រោម៖

- កំណត់នូវទស្សនវិស័យ និងសកម្មភាពសំខាន់ៗដែលត្រូវអនុវត្តរយៈពេល៥ឆ្នាំ (២០១៨-២០២២) ក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងសហគមន៍
- កំណត់នូវគោលការណ៍ប្រើប្រាស់ឱ្យបានសមស្រប និងការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌ និងតំលាភាពសំដៅជានាដល់ការគ្រប់គ្រងនៅក្នុងសហគមន៍ប្រកបដោយសុខដុមរមនា
- លើកកម្ពស់ប្រសិទ្ធភាពលើការគ្រប់គ្រងរបស់សហគមន៍ឱ្យមានលក្ខណៈបច្ចេកទេស ស្របតាមទិដ្ឋភាពច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

## ៣. ស្ថានភាពសេដ្ឋកិច្ចសង្គម

### *៣-១ .សមាជិក និងកម្រិតជីវភាព*

សហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក មានការចូលរួមពីប្រជាពលរដ្ឋ ចំនួន៥ភូមិ រួមមាន ភូមិតាមាយ ភូមិតាអុក ភូមិត្រេះ ភូមិប្រទាល និងភូមិប្រៃ ឃុំអណ្តូងទឹក ស្រុកបុទុមសាគរ ខេត្តកោះកុង ដែលបច្ចុប្បន្ននេះមានសមាជិកសរុបចំនួន **៥៣៣គ្រួសារ** ។ មុខរបរសំខាន់ៗសំខាន់ៗរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់នេះគឺ ការនេសាទ ធ្វើស្រែវស្សា និងការងារចិញ្ចឹមសត្វ។ ក្រៅពីនេះសមាជិកសហគមន៍មានមុខរបរបន្ទាប់បន្សំមួយចំនួនដូចជា៖ លក់កំលាំងពលកម្ម ធ្វើចំការ និងលក់ដូរ។

ដោយឡែកទាក់ទងទៅនឹងកម្រិតជីវភាព ក្នុងពេលបច្ចុប្បន្ននេះសមាជិកសហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក មានកម្រិតជីវភាពចែកចេញជាបីប្រភេទគឺ៖ សមាជិកដែលមានកម្រិតជីវភាពធូរធារ **១៥%** មធ្យមប្រមាណ**៣៥%** សមាជិក ដែលមានកម្រិតជីវភាពក្រីក្រប្រមាណ**៤៥%** និងសមាជិកដែលមានកម្រិតជីវភាពទីទាល់ក្រមានប្រមាណ**៥%**។




(**កំណត់សំគាល់៖** ប្រភព TST ធ្វើនៅខែធ្នូ ឆ្នាំ២០១៦ អ្នកចូលរួម២៨នាក់ ស្ត្រី៤នាក់)

### *៣-២ .ស្ថានភាពសន្តិសុខស្បៀង*

ស្ថានភាពសន្តិសុខស្បៀងនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក មានទំនាក់ទំនងជាមួយនឹងប្រភពចំណូលដែលសហគមន៍ទទួលបាននៅកំឡុងឆ្នាំនីមួយៗ។ យោងតាមលទ្ធផលនៃកិច្ចពិភាក្សា និង ផ្តល់យោបល់ដោយគណៈកម្មការសហគមន៍បានឱ្យដឹងថា សមាជិកសហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក មានប្រភពចំណូលមកពីការនេសាទ**២៥%** ធ្វើស្រែ(វស្សា)**២៥%** លក់កំលាំងពលកម្ម**២០%** ចិញ្ចឹមសត្វ**២០%** និងចំណូលពីការលក់ដូរ**១០%**។ បច្ចុប្បន្ននេះ សហគមន៍នៅមានភាពប្រឈមមួយចំនួនដូចជា បញ្ហាកង្វះដីសម្រាប់វិស័យកសិកម្ម និងកង្វះទឹកសាបប្រើប្រាស់ដែលបញ្ហានេះបានជះឥទ្ធិពលទៅដល់សន្តិសុខស្បៀងនៅក្នុងសហគមន៍ផងដែរ។




(**កំណត់សំគាល់៖** ប្រភព TST ធ្វើនៅខែធ្នូ ឆ្នាំ២០១៦ អ្នកចូលរួម២៨នាក់ ស្ត្រី៤នាក់)

### ៣-៤ .សមិទ្ធផលសំខាន់ៗដែលសហគមន៍សម្រេចបានកន្លងមក

នៅក្នុងដំណើរការគ្រប់គ្រងសហគមន៍រយៈពេលជាង១០ឆ្នាំកន្លងមកនេះ សហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក ទទួលបាននូវលទ្ធផលសំខាន់ៗមាន ដូចជា៖

- ការទទួលបាននូវសិទ្ធិពេញលេញក្នុងការគ្រប់គ្រង និងប្រើប្រាស់ផល-អនុផលព្រៃឈើសម្រាប់ការដោះស្រាយជីវភាពប្រចាំថ្ងៃរបស់សមាជិកសហគមន៍
- ការបោះបង្គោលព្រំប្រទល់សហគមន៍បាន១០៤បង្គោល
- រៀបចំបង្កើតក្រុមឥណទាននៅក្នុងសហគមន៍
- ការដកហូតឈើសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសហគមន៍ និងឧបត្ថម្ភដល់សមាជិកសម្រាប់ការសាងសង់លំនៅដ្ឋាន
- ការកសាងសមត្ថភាពគណៈកម្មការសហគមន៍ និងការចូលរួមគាំទ្រពីសមាជិកសហគមន៍
- កិច្ចសហការគាំទ្រពីស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋានលើការងារគ្រប់គ្រងធនធានធម្មជាតិនៅក្នុងសហគមន៍។

### ៣-៥ .បញ្ហាកំពុងជួបប្រទះ

ទន្ទឹមនឹងភាពរីកចម្រើនដែលសហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹកទទួលបាន សហគមន៍ក៏នៅមានបញ្ហាមួយចំនួនដែលកំពុងជួបប្រទះ ដូចជា៖

- បទល្មើសនេសាទពីអ្នកខាងក្រៅ នៅក្នុងដែនសហគមន៍
- សមត្ថភាពគណៈកម្មការសហគមន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅមានកម្រិត
- កង្វះធនធានមនុស្សដើម្បីចូលរួមក្នុងការដឹកនាំការងារគ្រប់គ្រងធនធានធម្មជាតិ
- កង្វះហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពាន និងទំនប់ទឹកការពារទឹកប្រៃ
- កង្វះដីសម្រាប់អនុវត្តន៍វិស័យកសិកម្ម

## ៤ .ស្ថានភាពទូទៅនៃធនធានរបស់សហគមន៍

### ៤-១. ធនធានធម្មជាតិក្នុងតំបន់ព្រៃសហគមន៍

ផ្អែកតាមលទ្ធផលនៃការធ្វើសារពើភ័ណ្ឌព្រៃសហគមន៍ បានបង្ហាញឱ្យឃើញថា នៅក្នុងសហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក ដែលមានទំហំផ្ទៃដីព្រៃសរុបចំនួន**១២៨៦ហិកតា** ក្នុងនោះសហគមន៍បានធ្វើការបែងចែកជាបីតំបន់សម្រាប់ធ្វើគ្រប់គ្រងនិងប្រើប្រាស់ ដែលរួមមាន តំបន់ប្រើប្រាស់ (ស្ថិតនៅតំបន់ព្រែកតាអុក និងជីត្រេះ) តំបន់អភិរក្ស(ស្ថិតនៅព្រែកផ្លោង) និងតំបន់ថែទាំកូនដំណុះធម្មជាតិ(ស្ថិតនៅព្រែកកន្ទួតរហូតដល់ព្រែកផ្លោង)។ ដោយផ្អែកតាមលក្ខណៈភូមិសាស្ត្រព្រៃសហគមន៍ សម្រាប់ការធ្វើសារពើភ័ណ្ឌនេះ សហគមន៍បានឯកភាពធ្វើសារពើភ័ណ្ឌតែនៅក្នុងតំបន់ប្រើប្រាស់ដែលមានផ្ទៃដីទំហំ **២១៨ហិចតា** ។

**តារាងលទ្ធផលសារពើភ័ណ្ឌធនធានព្រៃឈើនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិអណ្ដូងទឹក**

| **មុខកាត់តូចជាង១០ ស.ម** | **មុខកាត់ពី ១០ - ១៥ ស.ម** | **មុខកាត់ធំជាង១៥ ស.ម** |
|---|---|---|
| ៥៨៤ដើម/ហិចតា | ២២៨ដើម/ហិចតា | មានតិចតួច |
| **តារាងសរុបនៅលើផ្ទៃដី២១៨ហិចតា** | | |
| ១២៧៣១២ដើម | ៤៩៧០៤ដើម | មានតិចតួច |

(ប្រភព: ការសិក្សាប៉ាន់ប្រមាណពីធនធានព្រៃឈើនៅក្នុងសហគមន៍ ខែវិច្ឆិកា ឆ្នាំ ២០១៦)

### *៤-២ .តម្រូវការប្រើប្រាស់ផល អនុផលព្រៃឈើនៅក្នុងសហគមន៍*

តាមលទ្ធផលនៃការសិក្សាប៉ាន់ប្រមាណពីតម្រូវការប្រើប្រាស់ផល-អនុផលព្រៃឈើនៅក្នុងសហគមន៍ អាចកំណត់បានពីប្រភេទផលនិងអនុផលព្រៃឈើ ដែលជាតម្រូវការប្រើប្រាស់ចាំបាច់របស់សមាជិកសហគមន៍ សម្រាប់ការប្រកបរបរចិញ្ចឹមជីវិតប្រចាំឆ្នាំ។ ម៉្យាងទៀតលទ្ធផលនៃការសិក្សានេះ បានបង្ហាញអំពីបរិមាណនៃការប្រើប្រាស់ផល-អនុផលព្រៃឈើក្នុងរយៈមួយឆ្នាំនៅសហគមន៍។ ជាមួយគ្នា នេះយើងជឿជាក់ថាតួលេខនៃការប៉ាន់ប្រមាណទាំងនេះប្រាកដជាមានភាពលំអៀង ព្រោះថាព័ត៌មានដែលផ្ដល់ឱ្យតាមរយៈសមាជិកសហគមន៍នៅមានលក្ខណៈមិនប្រាកដ មិនជាក់លាក់ ហើយម៉្យាងទៀតបរិមាណនៃការប្រើប្រាស់នៅក្នុងគ្រួសារនីមួយៗ អាចមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំអាស្រ័យលើតម្រូវការទីផ្សារ និងការកើនឡើងនូវចំនួនសមាជិកនៅក្នុងគ្រួសារនីមួយៗផងដែរ។

**តារាងសិក្សាពីតម្រូវការប្រើប្រាស់ផល-អនុផលឈើជាមធ្យមនៅក្នុងសហគមន៍**

| **ល.រ** | **ប្រភេទនៃការប្រើប្រាស់** | **បរិមាណ** |
|---|---|---|
| ១ | ការសាងសង់លំនៅដ្ឋាន | ៩០ - ១០០ ដើម |
| ២ | ការធ្វើរបង់ផ្ទះ | ៥០ - ៨០ ដើម |
| ៣ | ការធ្វើរបង់ស្រែចំការ | ៨០ - ១០០ ដើម |
| | ចំអិនអាហារ | ៣រទេះគោយន្ត |
| | ទ្រុងមាន់ ទ្រុងទា | ៥០ - ៨០ ដើម |
| | ទ្រុងជ្រូក | ៥៥ដើម |
| | ក្រោលគោ ក្របី | ៤៥ដើម |

(ប្រភព: ការសិក្សាប៉ាន់ប្រមាណពីតម្រូវការប្រើប្រាស់ ខែវិច្ឆិកា ឆ្នាំ ២០១៦)

## ៥. យុទ្ធសាស្ត្រនៃការគ្រប់គ្រង

### *៥-១. រចនាសម្ព័ន្ធគ្រប់គ្រង*

សហគមន៍តំបន់ការពារធម្មជាតិអណ្ដូងទឹក មានសមាសភាពគណៈកម្មការចំនួន ១១នាក់ ក្នុងនោះមានស្ត្រីចំនួន៣នាក់ និងអមដោយទីប្រឹក្សាដែលមានមេភូមិ និងអ្នកគាំទ្ររួមមាន មន្ទីរបរិស្ថាន ឧទ្យានជាតិបុទុមសាគរ គម្រោងនិងអង្គការដៃគូ ។ សមាសភាពគណៈកម្មការទាំងនេះ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយសេរី និងមានដេកាទទួលស្គាល់ពីមេឃុំអណ្ដូងទឹក។




### *៥-២. ការបែងចែកតំបន់គ្រប់គ្រង និងប្រើប្រាស់*

ដោយផ្អែកទៅតាមស្ថានភាពភូមិសាស្ត្រនិងប្រភេទព្រៃ សហគមន៍បានធ្វើការបែងចែកជា **៣តំបន់**សំខាន់ៗដើម្បីធ្វើការគ្រប់គ្រងនិងការប្រើប្រាស់ ដែលរួមមាន៖ តំបន់ប្រើប្រាស់ តំបន់អភិរក្ស និងងតំបន់ថែទាំកូនជំណុះធម្មជាតិ(ដូចមានផែនទីបង្ហាញក្នុងតារាងឧបសម្ព័ន្ធ)។ គោលបំណងនៃការគ្រប់គ្រង និងការប្រើប្រាស់ក្នុងតំបន់នីមួយៗមាន ដូចខាងក្រោម៖

**តំបន់ប្រើប្រាស់** : តំបន់ប្រើប្រាស់នេះមានទំហំផ្ទៃដីសរុប **២២០ហិចតា** គោលបំណងនៃការគ្រប់គ្រងតំបន់នេះ គឺដើម្បីធ្វើការដកហូត និងប្រើប្រាស់ជាលក្ខណៈប្រពៃណី និងសម្រាប់សមាជិកធ្វើការសាងសង់ និងជួសជុលលំនៅដ្ឋាន ការប្រើប្រាស់សម្រាប់ជីវភាពប្រចាំថ្ងៃ ព្រមទាំងសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានានៅក្នុងសហគមន៍។

**តំបន់អភិរក្ស** : តំបន់នេះមានទំហំផ្ទៃដី**៨១៦ហិចតា** គោលបំណងនៃការគ្រប់គ្រងតំបន់នេះសំដៅការថែរក្សាជីវចម្រុះ និងប្រភេទឈើសំខាន់ៗ។ នៅតំបន់នេះមិនអនុញ្ញាតឱ្យធ្វើការដកហូតផល អនុផលព្រៃឈើគ្រប់ប្រភេទ ប៉ុន្តែសមាជិកសហគមន៍តំបន់ការពារធម្មជាតិអណ្ដូងទឹក អាចធ្វើការនេសាទជាលក្ខណៈគ្រួសារ ដោយគោរពទៅតាមលក្ខន្តិកៈរបស់សហគមន៍។

**តំបន់ថែទាំកូនដំណុះធម្មជាតិ** : តំបន់នេះមានទំហំផ្ទៃដី**២២០ហិចតា** គោលបំណងនៃការគ្រប់គ្រងតំបន់នេះសំដៅការថែកូនដំណុះធម្មជាតិ ជីវៈចម្រុះ ប្រភេទឈើសំខាន់ៗ និងសម្រាប់ដាំស្តារព្រៃឡើងវិញ។ នៅតំបន់នេះមិនអនុញ្ញាតឱ្យធ្វើការដកហូតផល អនុផលព្រៃឈើគ្រប់ប្រភេទ។

### *៥-២ .គោលការណ៍ប្រើប្រាស់ធនធានធម្មជាតិ*

ដោយយោងទៅតាមស្ថានភាពព្រៃ និងតម្រូវការប្រើប្រាស់ចាំបាច់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់សមាជិកសហគមន៍ ការរៀបចំផែនការគ្រប់គ្រងលើកទីមួយ(២០១៨-២០២២) សហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក បានកំណត់នូវគោលការណ៍ប្រើប្រាស់ ដូចខាងក្រោម៖

- ផ្អែកលើការសិក្សាប៉ាន់ប្រមាណពីធនធម្មជាតិនៅក្នុងសហគមន៍ សម្រាប់ផែនការលើកទី១ គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក មិនអនុញ្ញាតឱ្យធ្វើការដកហូតប្រភេទឈើកោងកាងសម្រាប់ប្រើប្រាស់ឡើយ
- មិនអនុញ្ញាត្តឱ្យកាប់ឈើគ្រប់ប្រភេទដើម្បីធ្វើអាជីវកម្មឡើយ
- មិនអនុញ្ញាត្តឱ្យដកហូត និងប្រើប្រាស់ឈើគ្រប់ប្រភេទ សំរាប់ប្រើប្រាស់ជាមធ្យោយបាយនេសាទឡើយ
- ការសាងសង់លំនៅដ្ឋានថ្មី អាចអនុញ្ញាត្តបានត្រឹម ១៥ខ្នងផ្ទះ ក្នុងមួយឆ្នាំ (៣ខ្នងផ្ទះក្នុង១ភូមិ) ហើយលទ្ធភាពនៃការផ្តល់ឈើ ជូនត្រឹមតែ៦០ដើម ទៅ ៨០ដើម ក្នុងមួយខ្នងផ្ទះ
- ការជួលជុលលំនៅដ្ឋាន សហគមន៍អនុញ្ញាត្តបានត្រឹម១៥ខ្នងផ្ទះ(៣ខ្នងផ្ទះក្នុង១ភូមិ) ចំពោះលទ្ធភាពនៃការផ្តល់ឈើ បានត្រឹម៣០ដើម ទៅ៥០ដើម ក្នុងមួយខ្នងផ្ទះ ហើយរយៈពេល៣ឆ្នាំទើបអាចស្នើសុំជួលជុលម្តងទៀត
- ការប្រើប្រាស់ឈើសម្រាប់សាងសង់ទ្រុងជ្រូក មាន់ ទា សហគមន៍អនុញ្ញាតបានត្រឹម១៥ខ្នងផ្ទះក្នុង១ឆ្នាំ(៣ខ្នងផ្ទះក្នុង១ភូមិ) ហើយលទ្ធភាពនៃការផ្តល់ជូនទៅតាមទំហំនៃការស្នើសុំ
- ការធ្វើរបងស្រែ ចំការ សហគមន៍អាចផ្តល់ជូនត្រឹម ៥០គ្រួសារ ក្នុង១ឆ្នាំ ហើយលទ្ធភាពនៃការផ្តល់ឈើបានត្រឹម៥០ដើម-១០០ដើម/គ្រួសារ
- ការធ្វើរបងផ្ទះ អាចផ្តល់ជូនបានអាចអនុញ្ញាតិបានត្រឹម៥០គ្រួសារ ហើយលទ្ធភាពផ្តល់ឈើបានត្រឹម៣០ដើម-៥០ដើម/គ្រួសារ
- ការសម្រេចផ្តល់ឈើទៅឱ្យគ្រួសារជាសមាជិកណាមួយ ត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍
- ការដកហូតឈើសំណង់ អាចធ្វើឡើងតែនៅក្នុងតំបន់ប្រើប្រាស់ និងកាប់តាមរបៀបជ្រើសរើស
- ប្រជាជនដែលមិនមែនជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក មិនអនុញ្ញាតឱ្យប្រើប្រាស់ធនធានព្រៃឈើនៅក្នុងតំបន់ព្រៃសហគមន៍ឡើយ

- ក្នុងករណីមានតម្រូវការប្រើប្រាស់ឈើសំរាប់បំរើសេចក្ដីត្រូវការនៅក្នុងសហគមន៍( សាលារៀន ស្នាក់ការសហគមន៍ វត្តអារាម ស្ពាន..) គណៈកម្មការសហគមន៍ត្រូវប្រជុំពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍ជាមុនសិន
- ការដកហូតនិងប្រើប្រាស់ធនធានព្រៃឈើនៅក្នុងសហគមន៍ ត្រូវធ្វើលិខិតជាលាយលក្ខអក្សរទៅគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិអណ្ដូងទឹក ដោយមានការដឹងឮពីមេឃុំអណ្ដូងទឹក និងមានការឯកភាពពីនាយកឧទ្យានជាតិបុទុមសាគរ ។

## *៥-៣. គោលការណ៍បែងចែកផលប្រយោជន៍*

ការបែងចែកផលប្រយោជន៍ គឺជាកត្តាសំខាន់មួយនៅក្នុងការគ្រប់គ្រងសហគមន៍ ប្រសិនបើការបែងចែកផលប្រយោជន៍ មិនប្រកបដោយសមធម៌ គ្មានតម្លាភាព នោះវាជាមូលហេតុធ្វើឱ្យមានទំនាស់កើតឡើង ឬអាចឈានទៅដល់ភាពបរាជ័យនៅក្នុងការគ្រប់គ្រងរបស់សហគមន៍ទាំងមូល។ សម្រាប់ការរៀបចំផែនការគ្រប់គ្រងលើកទីមួយនេះ សហគមន៍តំបន់ការពារធម្មជាតិអណ្ដូងទឹក បានកំណត់នូវគោលការណ៍បែងចែកផលប្រយោជន៍មួយចំនួន ដូចខាងក្រោម៖

- សមាជិកសហគមន៍សហគមន៍ដែលមានជីវភាពទីទាល់ក្រ និងងាយរងគ្រោះ មានអាទិភាពក្នុងការទទួលបានឈើសម្រាប់ការជួសជុល និងសាងសង់លំនៅដ្ឋានថ្មី
- ប្រជាពលរដ្ឋដែលមិនមែនជាសមាជិកសហគមន៍តំបន់ការពារធម្មជាតិអណ្ដូងទឹក មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ផល អនុផលព្រៃឈើនៅក្នុងតំបន់ព្រៃសហគមន៍ឡើយ
- រាល់ការដកហូតឈើសម្រាប់ប្រើប្រាស់គ្រប់ប្រភេទ ត្រូវមានលិខិតស្នើសុំជាលាយលក្ខអក្សរទៅគណៈកម្មការសហគមន៍ និងត្រូវមានការដឹងឮពីមេឃុំអណ្ដូងទឹក ព្រមទាំងមានការឯកភាពពីនាយកឧទ្យានជាតិបុទុមសាគរ
- ការដកហូតឈើសម្រាប់ប្រើប្រាស់នៅក្នុងតំបន់ព្រៃសហគមន៍គ្រប់រូបភាពទាំងអស់ ត្រូវធ្វើឡើងតាមរយៈការប្រជុំប្រចាំខែរបស់សហគមន៍ និងត្រូវមានការត្រួតពិនិត្យត្រឹមត្រូវពីគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិអណ្ដូងទឹក។

## *៥-៤ .គោលការណ៍ស្វែងរកថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុ*

- ប្រភពប្រាក់ចំណូលសហគមន៍តំបន់ការពារធម្មជាតិបឹងកាឆាង រួមមាន៖
  - ❖ ការប្រាក់ពីក្រុមសន្សំ
  - ❖ ប្រាក់ភាគទានសមាជិកសហគមន៍
  - ❖ សំណងការខូចខាត
  - ❖ ប្រាក់ចំណូលពីការបង់សេវាបរិស្ថាននៅក្នុងសហគមន៍

- ❖ សប្បុរសជន/អង្គការដៃគូ

- ថវិកាសហគមន៍ដែលទទួលបានពីគ្រប់ប្រភពទាំងអស់ មិនអនុញ្ញាតឱ្យធ្វើការប្រើប្រាស់ជាលក្ខណៈបុគ្គលឡើយ ពោលគឺទុកសម្រាប់បម្រើផលប្រយោជន៍រួមលើការងារអភិរក្ស និងការងារអភិវឌ្ឍន៍នៅក្នុងសហគមន៍តែប៉ុណ្ណោះ
- ប្រាក់ចំណូលដែលបានមកពីគ្រប់ប្រភពទាំងអស់ ត្រូវដាក់បញ្ចូលនៅក្នុងកេសសហគមន៍តែមួយ និងមានការកត់ត្រាក្នុងបញ្ជីច្បាស់លាស់ដោយហិរញ្ញិករបស់សហគមន៍
- ហិរញ្ញិកសហគមន៍ត្រូវធ្វើការបូកសរុប និងរាយការណ៍នៅរៀងរាល់ពេលកិច្ចប្រជុំប្រចាំខែនីមួយៗ
- ក្នុងករណីសហគមន៍មានថវិកាចំណូល ត្រូវធ្វើការបែងចែកទៅលើ៖ ការងារអភិរក្ស **៣០%** ការងារអភិវឌ្ឍន៍ **២០%** ការងារជួយសង្គ្រោះដល់សមាជិកសហគមន៍ **១០%** ការងាររដ្ឋបាល **២០%** ការងារវិស័យអប់រំ**៥%** និងសំរាប់តំកល់ទុកក្នុងកេសសហគមន៍ចំនួន**២០%**
- ថវិកាតំកល់ទុកក្នុងកេសសហគមន៍អាចរក្សាត្រឹមតែ **៥០០០.០០០រៀល** (ប្រាំលានរៀល) ប្រសិនបើលើសពីនេះ ត្រូវទុកប្រើប្រាស់ជាទុនបង្វិលសម្រាប់ក្រុមសន្សំក្នុងសហគមន៍ឬផ្ញើរនៅធនាគាដែលនៅជិតសហគមន៍
- គណៈកម្មការត្រូវធ្វើរបាយការណ៍សង្ខេបពីលទ្ធផលសកម្មភាពការងារ និងភាពរីកចំរើនលើការងារគ្រប់គ្រងសហគមន៍ ទៅនាយកឧទ្យានជាតិបុទុមសាគរ និងចំលងជូនប្រធានក្រុមប្រឹក្សាឃុំអណ្តូងទឹក នៅរៀងរាល់ **៣ខែម្តង**
- គណៈកម្មការត្រូវផ្សព្វផ្សាយពីលទ្ធផលសកម្មភាព និងភាពរីកចំរើនលើកាងារគ្រប់គ្រងសហគមន៍ទៅដល់សមាជិកសហគមន៍នៅរៀងរាល់ពេលកិច្ចប្រជុំប្រចាំឆ្នាំរបស់សហគមន៍។

## ៦. ផែនការសកម្មភាពសំខាន់ៗសម្រាប់អនុវត្តរយៈពេល៥ឆ្នាំ(២០១៨-២០២២)

ដោយយោងទៅតាមទស្សនវិស័យរបស់សហគមន៍ក្នុងការរៀបចំ និងអនុវត្តន៍ផែនការគ្រប់គ្រងលើកទីមួយ(២០១៨-២០២២) សហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក បានកំណត់សកម្មភាពចំបងៗ ដូចមាននៅក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាព | ពេលវេលាអនុវត្ត | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | |
| ១ | រៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការសម្រាប់អាណ្តតិថ្មី | | | | | x | |
| ២ | ការងារល្បាត | x | x | x | x | x | |
| ៣ | ការងារជួសជុលថ្នាលបណ្តុះកូនឈើ និងដាំស្តារព្រៃឈើ | x | x | | | | ៥០០០កូន |
| ៤ | ដាំស្តាកូនកោងកាង | x | x | x | x | x | ២៥០០០កូន |
| ៥ | ការសាងសង់និងជួលជុលផ្លូវក្រាលគ្រួសក្រហមនិងផ្លូវលំនៅក្នុងសហគមន៍ | x | x | | | | ១៣០០ម៉ែត្រគ្រួសក្រហម និងផ្លូវលំ ១៩០០ម៉ែត្រ |
| ៦ | ការសាងសង់អណ្តូងទឹក និងបង្គន់អនាម័យនៅសហគមន៍ | x | x | | | | |
| ៧ | ការកសាងសមត្ថភាពដល់គណៈកម្មការ( ការងារគ្រប់គ្រងថវិកា ការសរសេរគម្រោងខ្នាតតូច ការសរសេរធ្វើរបាយការណ៍ ការសរសេរកំណត់ហេតុ និងការគ្រប់គ្រងធនធានធម្មជាតិ ) | x | x | x | x | x | |
| ៨ | រៀបចំបង្កើតនិងពង្រឹងក្រុមសន្សំប្រាក់នៅក្នុងសហគមន៍ | x | x | x | x | x | ៥ក្រុម |
| ៩ | ការងារសាងសង់ស្នាក់ការសហគមន៍ | | x | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១០ | ការងារផ្សព្វផ្សាយ និងផ្តល់បទពិសោធន៍លើការងារគ្រប់គ្រងសហគមន៍ | x | x | x | x | x | |
| ១១ | សិក្សាសក្តានុពលតំបន់អេកូទេសចរណ៍នៅក្នុងសហគមន៍ | x | x | | | | |
| ១២ | ការធ្វើអាជីវកម្មខ្នាតតូចដើម្បីលើកកម្ពស់ជីវភាពសហគមន៍ | x | x | x | x | x | |
| ១៣ | រៀបចំផែនការគ្រប់គ្រងសហគមន៍លើកទី២ | | | | | x | |
| ១៤ | ទិវាបរិស្ថាននៅក្នុងសហគមន៍ | x | x | x | x | x | |
| ១៥ | សិក្សាទីតាំងនិងស្នើសុំពង្រីកផ្ទៃដីសហគមន៍បន្ថែម | x | | | | | |
| ១៦ | សន្និបាតបូកសរុបលទ្ធផលការងារប្រចាំរបស់សហគមន៍ | x | x | x | x | x | |

## តារាងផែនការសកម្មភាពសំរាប់អនុវត្តន៍ប្រចាំឆ្នាំ ២០១៨

| ល.រ | សកម្មភាព | ទីកន្លែង | អ្នកចូលរួម | ខែ | | | | | | | | | | | | ផ្សេង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១ | កិច្ចប្រជុំប្រចាំខែ | ស្នាក់ការ | គណៈកម្មការ | x | x | x | x | x | x | x | x | x | x | x | x | |
| ២ | ប្រជុំឆមាស និងប្រចាំឆ្នាំ | ស្នាក់ការ | គណៈកម្មការ | | | | | | x | | | | | | x | |
| ៣ | ការងារយាមល្បាត | ព្រៃសហគមន៍ | គណៈកម្មការ និងសមាជិក | x | x | x | x | x | x | x | x | x | x | x | x | |
| ៤ | ផ្សព្វផ្សាយផែនការគ្រប់គ្រង | ស្នាក់ការ | គណៈកម្មការ និងសមាជិក | | | | | | | | | | | x | x | |
| ៥ | ជួសជុលថ្នាលនិងបណ្តុះកូនកោងកាង | សហគមន៍ | គណៈកម្មការ និងសមាជិក | | | x | x | | | | | | | | | ២៥,០០០កូន |
| ៦ | ពិធីដាំកូនកោងកាង | ព្រៃសហគមន៍ | គណៈកម្មមការ និងសមាជិក | | | | | | | | x | x | x | x | x | ២៥,០០០កូន |
| ៧ | សាងសង់បង្គន់អណាម័យ | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | | | | | x | x | x | ៣៥០កន្លែង |
| ៨ | ការងារគ្រប់គ្រងនិងពង្រឹងក្រុមសន្សំប្រាក់ | សហគមន៍ | គណៈកម្មការ និងសមាជិក | x | x | x | x | x | x | x | x | x | x | x | x | ៥ក្រុម |
| ៩ | ស្នើសុំពង្រីកផ្ទៃដីសហគមន៍បន្ថែម | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | | | | | | x | x | |

| ១០ | សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំរបស់សហគមន៍ | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | | | | | | | x | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|

**តារាងផែនការសកម្មភាពសំរាប់អនុវត្តន៍ប្រចាំឆ្នាំ ២០១៩**

| ល.រ | សកម្មភាព | ទីកន្លែង | អ្នកចូលរួម | ខែ | | | | | | | | | | | | ផ្សេង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១ | កិច្ចប្រជុំប្រចាំខែ | ស្នាក់ការ | គណៈកម្មការ | x | X | x | x | x | x | x | x | x | x | x | x | |
| ២ | ប្រជុំធមាស និងប្រចាំឆ្នាំ | ស្នាក់ការ | គណៈកម្មការ | | | | | | x | | | | | | x | |
| ៣ | ការងារយាមល្បាត | ព្រៃសហគមន៍ | គណៈកម្មការ និងសមាជិក | x | X | x | x | x | x | x | x | x | x | x | x | |
| ៤ | រៀបចំថ្នាល និងបណ្តុះកូនកោងកាង | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | x | x | | | | | | | | |
| ៥ | ពិធីដាំកូនកោងកាង | ព្រៃសហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | | | x | x | x | x | x | |
| ៦ | សាងសង់ទីស្នាក់ការសហគមន៍ | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | | | | | x | x | x | |
| ៧ | គ្រប់គ្រងក្រុមសន្សំប្រាក់ | សហគមន៍ | គណៈកម្មការ និងសមាជិក | x | x | x | x | x | x | x | x | x | x | x | x | |
| ៨ | សាងសង់អណ្តូងស្នប់ | សហគមន៍ | គណៈកម្មការ និងសមាជិក | x | x | | | | | | | | | | | ៦៩អណ្តូង |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៩ | ការសាងសង់និងជួលជុលផ្លូវក្រាលគ្រួសក្រហមសហគមន៍ | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | | | | | x | x | x | |
| ១០ | ការងារគ្រប់គ្រង និងពង្រឹងក្រុមសន្សំប្រាក់នៅក្នុងសហគមន៍ | សហគមន៍ | គណៈកម្មការ និងសមាជិក | x | x | x | x | x | x | x | x | x | x | x | x | |
| ១១ | ទិវាបរិស្ថាននៅក្នុងសហគមន៍ | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | x | | | | | | | |
| ១២ | សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំរបស់សហគមន៍ | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | | | | | | | x | |

## តារាងផែនការសកម្មភាពសំរាប់អនុវត្តន៍ប្រចាំឆ្នាំ ២០២០

| ល.រ | សកម្មភាព | ទីកន្លែង | អ្នកចូលរួម | ខែ | | | | | | | | | | | | ផ្សេង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១ | កិច្ចប្រជុំប្រចាំខែ | ស្នាក់ការ | គណៈកម្មការ | x | x | x | x | x | x | x | x | x | x | x | x | |
| ២ | ប្រជុំឆមាស និងប្រចាំឆ្នាំ | ស្នាក់ការ | គណៈកម្មការ និងសមាជិក | | | | | | x | | | | | | x | |
| ៣ | ការងារយាមល្បាត | ព្រៃសហគមន៍ | គណៈកម្មការ និងសមាជិក | x | x | x | x | x | x | x | x | x | x | x | x | |
| ៤ | ការងារគ្រប់គ្រងនិងពង្រឹងក្រុមសន្សំប្រាក់នៅក្នុងសហគមន៍ | សហគមន៍ | គណៈកម្មការ និងសមាជិក | x | x | x | x | x | x | x | x | x | x | x | x | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៥ | សាងសង់និងជួសជុលផ្លូវលំនៅភូមិតាអុក | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | | | | | x | x | x | |
| ៦ | ទិវាបរិស្ថាននៅក្នុងសហគមន៍ | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | x | | | | | | | |
| ៧ | សន្និបាតបូកសុបលទ្ធផលការងារប្រចាំឆ្នាំរបស់សហគមន៍ | ស្នាក់ការ | គណៈកម្មការ និងសមាជិក | | | | | | | | | | | | x | |

## តារាងផែនការសកម្មភាពសំរាប់អនុវត្តន៍ប្រចាំឆ្នាំ ២០២១

| ល.រ | សកម្មភាព | ទីកន្លែង | អ្នកចូលរួម | ខែ | | | | | | | | | | | | ផ្សេង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១ | កិច្ចប្រជុំប្រចាំខែ | ស្នាក់ការ | គណៈកម្មការ | x | x | x | x | x | x | x | x | x | x | x | x | |
| ២ | ប្រជុំធមាស និងប្រចាំឆ្នាំ | ស្នាក់ការ | គណៈកម្មការ និងសមាជិក | | | | | | x | | | | | | x | |
| ៣ | ការងារយាមល្បាត | ព្រៃសហគមន៍ | គណៈកម្មការ និងសមាជិក | x | x | x | x | x | x | x | x | x | x | x | x | |
| ៤ | ការងារគ្រប់គ្រងនិងពង្រឹងក្រុមសន្សំប្រាក់នៅក្នុងសហគមន៍ | សហគមន៍ | គណៈកម្មការ | x | x | | | | | | | | | | | |
| ៥ | សិក្សាសក្តានុពលតំបន់អេកូទេសចរណ៍ | ព្រៃសហគមន៍ | គណៈកម្មការ និងសមាជិក | | | x | x | | | | | | | | | |
| ៦ | ទិវាបរិស្ថាននៅក្នុងសហគមន៍ | សហគមន៍ | គណៈកម្មការ | | | | | | x | | | | | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | និងសមាជិក | | | | | | | | | | | | | |
| ៧ | សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំរបស់សហគមន៍ | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | | | | | | | x | |

## តារាងផែនការសកម្មភាពសំរាប់អនុវត្តន៍ប្រចាំឆ្នាំ ២០២២

| ល.រ | សកម្មភាព | ទីកន្លែង | អ្នកចូលរួម | ខែ | | | | | | | | | | | | ផ្សេង |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១ | កិច្ចប្រជុំប្រចាំខែ | ស្នាក់ការ | គណៈកម្មការ | x | x | x | x | x | x | x | x | x | x | x | x | |
| ២ | ប្រជុំធមាស និងប្រចាំឆ្នាំ | ស្នាក់ការ | គណៈកម្មការ និងសមាជិក | | | | | | x | | | | | | x | |
| ៣ | ការងារយាមល្បាត | ព្រៃសហគមន៍ | គណៈកម្មការ និងសមាជិក | x | x | x | x | x | x | x | x | x | x | x | x | |
| ៤ | ការងារគ្រប់គ្រងនិងពង្រឹងក្រុមសន្សំប្រាក់នៅក្នុងសហគមន៍ | សហគមន៍ | គណៈកម្មការ | x | x | x | x | x | x | x | x | x | x | x | x | |
| ៥ | បោះឆ្នោតជ្រើសរើសគណៈកម្មការសម្រាប់អាណត្តិថ្មី | ស្នាក់ការ | គណៈកម្មការ និងសមាជិក | x | x | | | | | | | | | | | |
| ៦ | រៀបចំផែនការគ្រប់គ្រងសម្រាប់៥ឆ្នាំបន្ទាប់ | ស្នាក់ការ | គណៈកម្មការ និងសមាជិក | x | x | x | x | x | | | | | | | | |
| ៧ | ទិវាបរិស្ថាននៅក្នុងសហគមន៍ | សហគមន៍ | គណៈកម្មការ និងសមាជិក | | | | | | x | | | | | | | |

| | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៨ | សន្និបាតបូកសុរបលទ្ធផលការងារប្រចាំឆ្នាំរបស់សហគមន៍ | ស្នាក់ការ | គណៈកម្មការ និងសមាជិក | | | | | | | | | | | | x | |

## ៧.យន្តការត្រួតពិនិត្យ និងវាយតម្លៃ

ការត្រួតពិនិត្យនិងវាយតម្លៃ គឺជាមធ្យោបាយមួយដ៏សំខាន់សម្រាប់ជួយពង្រឹងដល់ដំណើរការអនុវត្តរបស់សហគមន៍ ក្នុងដំណើរការគ្រប់គ្រងធនធានធម្មជាតិ ក៏ដូចជាការងារអភិវឌ្ឍន៍សហគមន៍ ព្រមទាំងជួយសម្រេចឱ្យបាននូវគោលបំណង និងទស្សនវិស័យរបស់សហគមន៍។ ដំណើរការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការគ្រប់គ្រងនេះ សហគមន៍បានកំណត់នូវយន្តការត្រួតពិនិត្យ និងវាយតម្លៃ ដោយផ្អែកលើគោលការណ៍ទាំងបួននៃការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ប្រកបដោយនិរន្តរភាព ដូចមានខ្លឹមសារនៅក្នុងតារាងខាងក្រោម៖

**គោលការណ៍ទី១ ៖ ធនធានធម្មជាតិត្រូវបានថែរក្សា**

| លរ. | លក្ខណៈវិនិច្ឆ័យ | សូចនាករ |
|---|---|---|
| ១ | ការកំណត់តំបន់គ្រប់គ្រងច្បាស់លាស់ | មានផែនទីបង្ហាញពីតំបន់ព្រៃសហគមន៍ ចំនួនពីរផ្ទាំងសម្រាប់ផ្សព្វផ្សាយក្នុងសហគមន៍ |
| | | មានព្រំប្រទល់ច្បាស់លាស់ |
| | | សមាជិកសហគមន៍ ៨០% ស្គាល់ព្រំប្រទល់ព្រៃសហគមន៍ច្បាស់ |
| ២ | ជីវៈចម្រុះត្រូវបានថែរក្សា | សហគមន៍មានថ្នាលបណ្តុះកូនឈើសម្រាប់បណ្តុះនិងថែបំប៉នកូនដំណុះធម្មជាតិ |
| | | កូនកោងកាងចំនួន ២៥០០០កូន ត្រូវបានដាំស្តារនៅក្នុងតំបន់ថែទាំកូនដំណុះ |
| | | ប្រភេទសត្វមួយចំនួនមានការកើនឡើងក្នុងតំបន់ព្រៃសហគមន៍ |
| | | ប្រភេទឈើកម្រ និងធនធានជលផលត្រូវបានថែរក្សាការពារ |
| | | កូនដំណុះធម្មជាតិត្រូវបានថែរក្សា |

**គោលការណ៍ទី២ ៖ សុខមាលភាពសមាជិកត្រូវបានធ្វើឱ្យប្រសើរឡើង**

| លរ. | លក្ខណៈវិនិច្ឆ័យ | សូចនាករ |
|---|---|---|
| ១ | ធនធានព្រៃសហគមន៍បានរួមចំណែកទ្រទ្រង់ជីវភាពរស់នៅរបស់សមាជិកសហគមន៍ | សមាជិកសហគមន៍៨០% បានប្រើប្រាស់ផល អនុផលពីព្រៃសហគមន៍សម្រាប់ជីវភាពរស់នៅ |
| | | យ៉ាងហោចណាស់សមាជិកសហគមន៍ ៣០គ្រួសារ ក្នុងមួយឆ្នាំអាចទទួលបានឈើសំរាប់ជួសជុល និងសាងសង់លំនៅដ្ឋាន |

| | | |
|---|---|---|
| ២ | សមាជិកសហគមន៍ទទួលបានប្រាក់ចំណូលតាមរយៈការចូលរួមក្រុមប្រាក់សន្សំ | យ៉ាងហើយណាស់សមាជិកសហគមន៍ចំនួន១២០គ្រួសារ ទទួលបានប្រាក់ចំណូលតាមរយៈការចូលរួមក្នុងក្រុមសន្សំប្រាក់នៅក្នុងសហគមន៍ |
| ៣ | សមាជិកសហគមន៍ទទួលបានទឹកសាបនិងបង្គន់អនាម័យប្រើប្រាស់តាមគ្រួសារ | យ៉ាងហើចណាស់គ្រួសារជាសមាជិកសហគមន៍ប្រមាណ៧០% ទទួលបានអណ្តូងស្នប់ និងបង្គន់អនាម័យប្រើប្រាស់តាមគ្រួសារ |

### គោលការណ៍ទី៣ ៖ សុខមាលភាពសហគមន៍ត្រូវបានធានា

| លរ. | លក្ខណៈវិនិច្ឆ័យ | សូចនាករ |
|---|---|---|
| ១ | គណៈកម្មការសហគមន៍មានសមត្ថភាពដឹកនាំ | ទំនាស់ផ្សេងៗក្នុងសហគមន៍នឹងត្រូវបានដោះស្រាយដោយគណៈកម្មការ |
| | | ការគ្រប់គ្រងថវិកាមានភាពច្បាស់លាស់និងតម្លាភាព |
| | | ថវិកាប្រាក់សន្សំរបស់សហគមន៍មានការកើនឡើង |
| ២ | ការចូលរួមរបស់សមាជិកសហគមន៍ | រាល់ការប្រជុំនឹងមានសមាជិកចូលរួមលើសពី៦០% |
| | | សមាជិក៨០% បានចូលរួមយាមល្បាតនិងទប់ស្កាត់បទល្មើស |
| | | ៨០% នៃសមាជិកហ៊ានរាយការណ៍ពីអ្នកធ្វើបទល្មើសក្នុងព្រៃសហគមន៍ |
| | | សមាជិក៨០% បានសុំការអនុញ្ញាតពីគណៈកម្មការមុនការនឹងធ្វើការដកហូត និងប្រើប្រាស់ធនធាន |
| ៣ | ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសហគមន៍ត្រូវបានកែលំអរ | ផ្លូវក្រាលគ្រួសក្រហម១ខ្សែប្រវែង១៣០០ម៉ែត្រ និងផ្លូវលំ១ខ្សែប្រវែង១៩០០ម៉ែត្រ ត្រូវបានសាងសង់នៅក្នុងសហគមន៍ |
| | | ទំនប់បង្ហៀរទឹកប្រៃចំនួនបីកន្លែងត្រូវបានសាងសង់ |
| | | សហគមន៍មានស្នាក់ការសម្រាប់ប្រាស់ប្រើ |

គោលការណ៍ទី៤ ៖ មានការគាំទ្រពីមជ្ឈដ្ឋានខាងក្រៅ

| ល.រ. | លក្ខណៈវិនិច្ឆ័យ | សុចនាករ |
|---|---|---|
| ១ | ការចូលរួមពីក្រុមប្រឹក្សាឃុំ | កិច្ចប្រជុំនៅក្នុងសហគមន៍មានការចូលរួមពីមេឃុំអណ្ដូងទឹក និង ឧទ្យានជាតិបុទុមសាគរ |
| | | ៥០%នៃផែនការសកម្មភាពរបស់សហគមន៍ត្រូវបានដាក់បញ្ចូលក្នុងផែនការនិងកម្មវិធីអភិវឌ្ឍន៍ឃុំ |
| ២ | ការគាំទ្រពីស្ថាប័នជំនាញ | ផែនការគ្រប់គ្រងសម្រាប់រយៈពេល៥ឆ្នាំ(២០១៨-២០២២) ត្រូវបានគាំទ្រពីអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ក្រសួងបរិស្ថាន |

តារាងសកម្មភាពសម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ

| ល.រ | សកម្មភាព | អ្នកចូលរួម | វិធីសាស្ត្រ | ប្រធានបទ |
|---|---|---|---|---|
| ១ | ប្រជុំប្រចាំខែ | ប្រធានក្រុម, គណៈកម្មការ និងទីប្រឹក្សា | ប្រជុំពិភាក្សារួម | - ពិនិត្យលើផែនការប្រចាំខែ<br>- ដោះស្រាយបញ្ហាដែលកើតមាន |
| ២ | ប្រជុំប្រចាំឆមាស | ប្រធានក្រុម គណៈកម្មការ ទីប្រឹក្សា និងសមាជិក | - ប្រជុំពិភាក្សារួម<br>- ពិនិត្យជាក់ស្តែង<br>- ធ្វើការសំភាសន៍ | - ពិនិត្យលើផែនការ<br>- ដោះស្រាយបញ្ហាដែលកើតមាន<br>- ថវិកាសហគមន៍ |
| ៣ | ប្រជុំប្រចាំឆ្នាំ | ប្រធានក្រុម, គណៈកម្មការ ទីប្រឹក្សា, សមាជិក នាយកដែនជម្រក | - ប្រជុំពិភាក្សារួម<br>- ពិនិត្យជាក់ស្តែង<br>- ធ្វើការសំភាសន៍ | - ពិនិត្យលើផែនការប្រចាំខែ<br>- ដោះស្រាយបញ្ហាដែលកើតមាន |

## ៨. ឯកសារឧបសម្ព័ន្ធ

- សេចក្តីប្រកាសទទួលស្គាល់ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក
- ផែនទីសហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក
- ផែនទីបែងចែកតំបន់គ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិរបស់សហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក
- តារាងបញ្ជីឈ្មោះអ្នកចូលរួមពិគ្រោះយោបល់ព្រាងផែនការគ្រប់គ្រងសហគមន៍
- តារាងបញ្ជីឈ្មោះអ្នកចូលរួមពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍លើសេចក្តីព្រាងផែនការគ្រប់គ្រងសហគមន៍
- តារាងបញ្ជីឈ្មោះអ្នកចូលរួមសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធលើសេចក្តីព្រាងផែនការគ្រប់គ្រងតំបន់។

ថ្ងៃទី.០៦.....ខែ.កក្កដា.ឆ្នាំ ២០១៧
ប្រធានសហគមន៍តំបន់ការពារធម្មជាតិអណ្តូងទឹក

(ហត្ថលេខា)

លេខ.០២០០២/១៧
បានឃើញនិងគោរពជូន
លោកនាយកឧទ្យានជាតិបុទុមសាគរ
ដើម្បីពិនិត្យនិងជួយសម្រួល
អណ្តូងទឹក ថ្ងៃទី.០៧.....ខែ..កក្កដា.ឆ្នាំ ២០១៧
មេឃុំ

(ហត្ថលេខា និងត្រា)

ឃុំ_ យ៉េង

លេខ...០២២/១៧...
បានឃើញនិងគោរពជូន
លោកប្រធានមន្ទីរបរិស្ថានខេត្តកោះកុង
ដើម្បីពិនិត្យនិងជួយសម្រួល
បុទុមសាគរ,ថ្ងៃទី...១៧...ខែ...កញ្ញា...ឆ្នាំ ២០១៧
**នាយកឧទ្យានជាតិបុទុមសាគរ**

លេខ...........................
បានឃើញនិងគោរពជូន
ឯកឧត្តមអគ្គនាយក នៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន
ដើម្បីពិនិត្យនិងសម្រេច
កោះកុង,ថ្ងៃទី.........ខែ...តុលា...ឆ្នាំ ២០១៧
ប្រធានមន្ទីរបរិស្ថានខេត្តកោះកុង

**ម៉ិន ផល្លា**

លេខ...........................
បានឃើញនិងឯកភាព
រាជធានីភ្នំពេញ,ថ្ងៃទី...២៥...ខែ...តុលា...ឆ្នាំ ២០១៧
អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន

**ខៀវ ប៊ុរិន**